ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០២ សរ

**សារាចរ**
**ស្តីពី**
**ការពង្រឹងបន្ថែមលើការងារគ្រប់គ្រងសកម្មភាពមីន**

សកម្មភាពបោសសម្អាតមីនត្រូវបានរាជរដ្ឋាភិបាលកំណត់យកជាអាទិភាពចម្បង ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនិងជំរុញការអភិវឌ្ឍ។ ព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវចក្ខុវិស័យយ៉ាងច្បាស់លាស់ថា ប្រទេសកម្ពុជាជាប្រទេសដែលគ្មានមីន ការគំរាមកំហែងដោយសំណល់ជាតិផ្ទុះពីសង្គ្រាមត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍមនុស្សអាចប្រព្រឹត្តទៅដោយសុវត្ថិភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ដោយកំណត់យកឆ្នាំ២០២៥ ជាឆ្នាំដែលកម្ពុជាគ្មានមីន។ ដើម្បីសម្រេចបានជោគជ័យតាមផែនការយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលធ្វើការណែនាំដូចខាងក្រោម៖

១-ស្នើបន្តកិច្ចសហប្រតិបត្តិការគាំទ្ររបស់ដៃគូអភិវឌ្ឍ ប្រទេសជាមិត្ត វិស័យឯកជន និងសប្បុរសជន ទាំងផ្នែកបច្ចេកទេស ថវិកា និងសម្ភារ ក្នុងបេសកកម្មបោសសម្អាតមីននៅកម្ពុជា ដើម្បីឈានដល់ការសម្រេចបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ និងការសម្រេចបានគោលដៅ **កម្ពុជាគ្មានមីន** ត្រឹមឆ្នាំ២០២៥។

២-ក្រសួង ស្ថាប័ន ដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ ត្រូវសហការជាមួយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ដើម្បីពិគ្រោះយោបល់អំពីស្ថានភាពនៃការគម្រាមដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះលើទីតាំងដែលត្រូវអនុវត្តគម្រោង ក៏ដូចជាកំណត់នូវវិធានការចាំបាច់ និងវិធីសាស្ត្រដើម្បីបញ្ចៀសនូវហានិភ័យនានាដែលអាចកើតមាន។ ការចុះកិច្ចសន្យា ត្រូវធ្វើឡើងតែជាមួយប្រតិបត្តិករបោសសម្អាតមីន ដែលមានអាជ្ញាបណ្ណ និងបណ្ណទទួលស្គាល់នៅមានសុពលភាពពីអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីនប៉ុណ្ណោះ ដើម្បីលើកកម្ពស់ និងធានានូវការគោរពស្តង់ដានៃការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ប្រកបទៅដោយគុណភាព និងធានាបាននូវសុវត្ថិភាពពេញលេញ។

៣-គ្រប់ក្រុមហ៊ុនអាជីវកម្ម និងអ្នកសាងសង់គម្រោងឯកជន ត្រូវសហការនិងពិភាក្សាជាមួយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ដើម្បីកំណត់អត្តសញ្ញាណពិតប្រាកដនៃទីតាំងដែលមានការគម្រាមដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងចាំបាច់ត្រូវបោសសម្អាតជាមុន មុននឹងចាប់ផ្តើមអនុវត្តការសាងសង់ឬធ្វើសកម្មភាពនានារបស់ខ្លួន។

៤-សូមលើកទឹកចិត្តដល់ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធឱ្យបន្តយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសុខាភិបាលនិងព្យាបាលជំងឺដោយឥតគិតថ្លៃប្រកបដោយវិជ្ជាជីវៈដល់ប្រតិបត្តិករបោសសម្អាតមីន។

៥-អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្តនិងឯកសារពាក់ព័ន្ធនានា ដើម្បីជានានូវសុខដុមនីយកម្មរចនាសម្ព័ន្ធនៃការគ្រប់គ្រងសកម្មភាពមីន និងត្រូវបន្តអនុវត្ត **យន្តការភូមិអស់មីន** ឱ្យបានជោគជ័យ។

៦-ប្រតិបត្តិករបោសសម្អាតមីនជាតិ អន្តរជាតិ ត្រូវសហការជាមួយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ក្នុងការពង្រឹងបន្ថែមលើការងារគ្រប់គ្រង សកម្មភាពមីន និងការបញ្ជូនកងកម្លាំងដែលជាជនជាតិខ្មែរក្នុងការងារ សកម្មភាពមីនទៅបំពេញបេសកកម្មនៅក្រៅប្រទេស។

៧-អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ត្រូវធ្វើការសិក្សាអំពីលទ្ធភាពនៃការកាត់បន្ថយផ្ទៃដីដែលមានការគំរាមដោយសារមីន តាមវិធីសាស្ត្រមិនបច្ចេកទេសប្រកបទៅដោយសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផលឱ្យបានពេញលេញតាមតែអាចធ្វើទៅបាន សំដៅបង្កើនល្បឿនការបោសសម្អាតមីននៅកម្ពុជា។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ប្រតិបត្តិករបោសសម្អាតមីន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ